**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៦០ សសរ

# សេចក្តីសម្រេច

**ស្តីពី**

**ការបង្កើតក្រុមការងារដើម្បីដឹកនាំ គ្រប់គ្រងទីប្រឹក្សា ជំនួយការ ឯកឧត្តម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែតុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ២៩ អនក្រ.បក ចុះថ្ងៃទី ២៣ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការបង្កើតខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា
- យោងតាមការចាំបាច់នៃការងារ

## សម្រេច

**ប្រការ ១.-** ត្រូវបានបង្កើតក្រុមការងារដែលមានសមាសភាពដូចខាងក្រោម ដើម្បីដឹកនាំ គ្រប់គ្រងទីប្រឹក្សា ជំនួយការ ឯកឧត្តម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ÷

១- ឯកឧត្តម **អ៊ុយ ស៊ីម** ទីប្រឹក្សា និងជានាយកខុទ្ទកាល័យ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី **ស ខេង** ប្រធាន

២- ឯកឧត្តមឧត្តមសេនីយ៍ឯក **ខៀវ សុភ័គ** នាយកខុទ្ទកាល័យរដ្ឋមន្ត្រី និងជាអគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋានក្រសួងមហាផ្ទៃ អនុប្រធាន

៣- ឯកឧត្តម **ឈឹម មង្គល** ជំនួយការឯកឧត្តមឧបនាយករដ្ឋមន្ត្រី **ស ខេង** លេខាធិការ

www.pheakdeylaw.com

**ប្រការ ២.-** ភារកិច្ចរបស់ក្រុមការងារ ៖

- ពាំនាំនូវបញ្ហា និងសេចក្តីណែនាំនានារបស់ឯកឧត្តម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជូនឯកឧត្តម អស់លោក ជាទីប្រឹក្សា ជំនួយការ ដើម្បីអនុវត្ត
- ពិនិត្យ និងផ្តល់យោបល់លើរាល់កិច្ចការ សំណុំឯកសារ លិខិត ឬសំណើនានារបស់ទីប្រឹក្សា ជំនួយការ ដែលត្រូវផ្ញើជូនឯកឧត្តម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ពិនិត្យ និងសំរេច
- ពិនិត្យ និងលើកយោបល់លើស្នាដៃការងាររបស់ទីប្រឹក្សា ជំនួយការ
- គ្រប់គ្រងសំណុំឯកសារផ្ទាល់ខ្លួនរបស់ឯកឧត្តម អស់លោកជាទីប្រឹក្សា ជំនួយការ
- បំពេញការងារផ្សេងៗទៀត តាមការប្រគល់ភារកិច្ចពីឯកឧត្តម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**ប្រការ ៣.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ ឯកឧត្តមដែលមានរាយនាមក្នុងប្រការ១ ទីប្រឹក្សា និងជំនួយការឯកឧត្តម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃទាំងអស់ ត្រូវអនុវត្តតាមសេចក្តីសម្រេចនេះ ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៨ ខែ វិច្ឆិកា ឆ្នាំ២០០៧

ឧបនាយករដ្ឋមន្ត្រី

**ស ខេង**

**កន្លែងទទួល :**

- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី ស **ខេង**
- ខុទ្ទកាល័យរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
- ដូចប្រការ៣
- ឯកសារ-កាលប្បវត្តិ

www.pheakdeylaw.com